# សមាគមច្បាប់អន្តរជាតិនៃកម្ពុជា

អត្ថបទស្រាវជ្រាវទី៧

****

# សិទ្ធិទទួលបាន
# ការវិនិច្ឆ័យសេចក្ដីក្នុងពេលវេលាសមស្រប
# និង សំណងក្នុងករណីមានការបំពាន

ដោយបណ្ឌិត មាស បូរ៉ា និងលោក ទិត វុធរ៉ាឌីន*

(ខែតុលា ឆ្នាំ២០២១)

* បណ្ឌិត **មាស បូរ៉ា** ជាអ្នកស្រាវជ្រាវច្បាប់ និងជាមេធាវី។ លោក **ទិត វុធរ៉ាឌីន** កំពុងសិក្សាថ្នាក់អនុបណ្ឌិតនីតិអន្តរជាតិសាធារណៈ នៅសាកលវិទ្យាល័យប៉ារីស៨ និងជាកម្មសិក្សាការីនៅសមាគមច្បាប់អន្តរជាតិនៃកម្ពុជា។

** សូមយោង÷ មាស បូរ៉ា និងទិត វុធរ៉ាឌីន, សិទ្ធិទទួលបានការវិនិច្ឆ័យសេចក្តីក្នុងពេលវេលាសមស្រប និងសំណងក្នុងករណីមានការបំពាន, សមាគមច្បាប់អន្តរជាតិនៃកម្ពុជា, ខែតុលា ឆ្នាំ២០២១។

# សិទ្ធិទទួលបានការវិនិច្ឆ័យសេចក្ដីក្នុងពេលវេលាសមស្រប និង សំណងក្នុងករណីមានការបំពាន

(Trial within Reasonable Time: TRT)

## ១. សេចក្ដីផ្ដើម

ដំណើរការក្ដីនៃរឿងព្រហ្មទណ្ឌ ចាប់ផ្ដើមពីដំណាក់កាលស៊ើបអង្កេតរហូតដល់សវនាការ ដែលអាចបញ្ចប់ក្នុងពេលវេលាខ្លី ឬមានការពន្យាយូរអាស្រ័យទៅតាមប្រភេទ ឬភាពស្មុគស្មាញ ឬងាយស្រួលនៃសំណុំរឿងនីមួយៗ។ ការពន្យាពេល អាចនាំឱ្យមានការបំពានសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្ដីក្នុងពេលវេលាសមស្រប ហើយជនរងគ្រោះ មានសិទ្ធិទទួលបាននូវសំណងតាមវិធានសិទ្ធិមនុស្ស ឬច្បាប់ជាតិ។

តាមរយៈការពិនិត្យច្បាប់ សន្ធិសញ្ញា និងយុត្តិសាស្ត្រ អត្ថបទនេះ នឹងបង្ហាញថា តើមានកត្តាអ្វីខ្លះ ដើម្បីកំណត់ថាសិទ្ធិនេះ ត្រូវបានបំពាន ហើយតើសំណងអ្វីខ្លះ នឹងត្រូវបានផ្ដល់ជូនជនរងគ្រោះ? ផ្នែកទីពីរ នឹងពិនិត្យនូវមូលដ្ឋានផ្លូវច្បាប់ ដែលតុលាការកម្ពុជា អាចអន្តរាគមន៍ ឆ្លើយតប ដែលមានដូចជាការផ្ដល់សំណងជូនជនរងគ្រោះនៃអំពើបំពានសិទ្ធិ។

## ២. ខ្លឹមសារក្នុងវិធាន និងយុត្តិសាស្ត្រ

សន្ធិសញ្ញាសិទ្ធិមនុស្ស ដែលរដ្ឋបានចូលជាភាគី បានចែងអំពីកាតព្វកិច្ច និងសិទ្ធិ។ ក្នុងនោះមានសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្ដីប្រកបដោយយុត្តិធម៌ដូចដែលមាត្រា១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិប្រជាពលរដ្ឋចែង÷ *១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្ដី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ... ៣.ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណា*

*មួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម÷...(គ) ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស។*[1]

ចំណុច **គ** បានចែងតម្រូវឱ្យសវនាការត្រូវបានធ្វើឡើងក្នុងពេលឆាប់ៗ និងបញ្ចប់ទៅក្នុងអំឡុងពេលវេលាសមស្រប។ ក្រៅពីចែងអំពីសិទ្ធិ កតិកាសញ្ញាបានចែងអំពីសិទ្ធិទទួលបាននូវដំណោះស្រាយចំពោះការបំពានសិទ្ធិ ទោះបីការបំពានត្រូវបានធ្វើឡើងដោយអាជ្ញាធររដ្ឋក្តី÷ *៣.រដ្ឋភាគី...ធានាថា ជនណាដែលត្រូវបានគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិទោះបីការរំលោភនោះបានប្រព្រឹត្ត ដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។*[2] ដូចនេះការបំពានសិទ្ធិចែងក្នុងមាត្រា១៤ (គ) ក៏តម្រូវឱ្យមានដំណោះស្រាយ (remedy) ផងដែរដល់ជនរងគ្រោះដែលពួកគេអាចជាជនសង្ស័យនៃការប្រព្រឹត្តបទល្មើសណាមួយ និងកំពុងស្ថិតនៅក្នុងនីតិវិធីរបស់តុលាការ។

ហេតុផលនៃវត្តមាននៃសិទ្ធិ TRT គឺដើម្បីជំរុញឱ្យមានសវនាការក្នុងពេលឆាប់ៗ ដោយសារ ការពន្យារយូរ នាំឱ្យសាក្សីបាត់បង់ការចងចាំ រីឯភស្តុតាងចម្បងក៏អាចខូចខាតដែលពិបាកដល់ចៅក្រមក្នុងការសម្រេចសេចក្តីឱ្យបានត្រឹមត្រូវនិងយុត្តិធម៌ ផ្អែកលើភស្តុតាងគ្រប់គ្រាន់។[3]

បើទោះបីជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង សវនាការតែងតែជៀសមិនរួចពីការពន្យារពេល ហើយការពន្យារនោះ នាំឱ្យមានការបំពានសិទ្ធិទទួលបានសវនាការក្នុងពេលសមស្រប។ ភាពយឺតយ៉ាវអាចចាប់ផ្តើមតាំងពីថ្ងៃឃាត់ខ្លួនរហូតដល់ថ្ងៃចេញសាលក្រមជាស្ថាពរ ដែលជួនកាលមានរយៈពេលជាង៥ឆ្នាំទៅដល់១០ ឆ្នាំ។[4] មានកត្តាជាច្រើននាំដែលនាំឱ្យមានភាពយឺតយ៉ាវដូចជា÷ **១.** ភាពស្មុគស្មាញនៃសំណុំ-

[1] UN General Assembly, *International Covenant on Civil and Political Rights*, 16 December 1966, United Nations, Treaty Series, vol. 999, p. 176-177, available at: https://www.refworld.org/docid/3ae6b3aa0.html [accessed 31 July 2021]

[2] *Id.*, មាត្រា ២។

[3] Amnesty International, Fair Trial Manual: Fair Trial and Judiciary, 2nd Ed., 2014, p.144.

[4] ៨ឆ្នាំ ផ្តើមពី ការឃាត់ខ្លួនរហូត សាលក្រមស្ថាពរ (*Scrrone v. Uruguay*), p.10 (violated article 14)។ ៣ឆ្នាំ ពីឃាត់ខ្លួន ដល់ សវនាការ (បំពាន ១៤) *Seerattan v. Trinidad*, p.13)។១០ ឆ្នាំ វសនាការ និង សវនាការ (បំពាន) *Dobbertin v. France*, p.23 (ECHR); 8 years ពេលសួរ និង សាលក្រម (បំពាន) *Hozee v. the Netherlands* p. 24) ECHR។

រឿង (អង្គហេតុកើតមានយូរហើយ និងមានមនុស្ស ពាក់ព័ន្ធជាច្រើន ក្នុងសំណុំរឿង)។[5] ទី២. មានភាពយឺតយ៉ាវពីសំណាក់អាជ្ញាធរ[6] និងទី៣. ភាពយឺតយ៉ាវបង្កដោយជនសង្ស័យខ្លួនឯង ដែលមានដូចជាការគេចខ្លួន ឬ បានប្តឹងតវ៉ា (ប្តឹងជិតចិត្ត) ជាដើម។[7] តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប បានសម្រេចថា *មានកត្តាពាក់ព័ន្ធចំនួនបីក្នុងការសម្រេចថា តើពេលវេលានៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មានភាពសមស្របដែរឬទេ? កត្តាទាំងបីនោះរួមមាន (១) អ្វីដែលជាបញ្ហាប្រឈមជាមួយអ្នកដាក់ពាក្យសុំ (២) លក្ខណៈ និងភាពស្មុគស្មាញនៃរឿងក្តី (៣) ការប្រព្រឹត្តិរបស់អ្នកដាក់ពាក្យក្នុងកិច្ចដំណើរការនីតិវិធី និង (៤) ការប្រព្រឹត្តិរបស់អាជ្ញាធររដ្ឋបាល និងអាជ្ញាធរតុលាការពាក់ព័ន្ធ។*[8]

សិទ្ធិ TRT ចងដល់តុលាការគ្រប់កម្រិត ចាប់តាំងពីរយៈពេលឃាត់ខ្លួន ឬការជូនដំណឹងជាផ្លូវការអំពីការចោទប្រកាន់ដល់សវនាការ។[9] ស្ថានភាពសេដ្ឋកិច្ច ឬការកកស្ទះសំណុំរឿងនៅតាមសាលាក្តី មិនត្រូវបានទទួលជាការដោះសារសម្រាប់ការពន្យារពេលទេ។[10] ក្នុងសំណុំរឿងមួយ តុលាការបានអះអាងថា ការយឺតយ៉ាវនេះបណ្តាលមកពីភាពមិនហ្មត់ចត់របស់អាជ្ញាធរ។[11] ជនត្រូវចោទអាចទទួលបានសំណង ប្រសិនបើអាចបង្ហាញក្នុងកម្រិតតុល្យភាពនៃអ្វីអាចកើតមានឡើង (balance of probability) ថាមិនមានយុត្តិធមិ

[5] DovydasVitkauskas and Grigory Dikov, Protecting right to a fair trial under the European Convention on Human Rights: A Handbook for legal practitioners, 2nd ed, p. 109.

[6] *Id.*,

[7] OSCE, Legal Digest of Fair Trial Rights, 2012, p.127-128.

[8] រឿងក្តី *Konig តទល់នឹង ប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការពេញអង្គ ពាក្យសុំលេខ 6232/73 ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៨) កថាខណ្ឌ៩៩។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Neumeister តទល់នឹង ប្រទេសអូទ្រីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ 1936/63 ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨) កថាខណ្ឌ២១។ រឿងក្តី *Ringeisen តទល់នឹង ប្រទេសអូទ្រីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ 2614/65 ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧១) កថាខណ្ឌ១១០។ រឿងក្តី *Pélissier និង Sassi តទល់នឹង ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ 25444/94 ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ៦៧។ រឿងក្តី *Pedersen និង Baadsgaard តទល់នឹង ប្រទេសដាណឺម៉ាក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ49017/99 ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៤៥។

[9] OSCE, legal digest, *supra* note 7, p. 128។

[10] Case of *Philis v. Greece*, European Court of Human Rights, Application no. 12750/87, Judgement, 27 August 191, p. 25.

[11] Jorge A. Giménez v. Argentina, Case 11.245, Report No. 12/96, Inter-Am.C.H.R., OEA/Ser.L/V/II.91 Doc. 7 at 33 (1996), p.28.

ដោយសារការកាត់សេចក្តីខុស (wrongful conviction) សវនាការយឺតយូរ ហួសពេក និងទទួលរងនូវការឈឺចាប់ (ផ្លូវចិត្ត)។[12]

យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សបានបង្ហាញថា ដើម្បីកំណត់ថា សិទ្ធិទទួលបានសវនាការក្នុងពេលសមស្រប ត្រូវបានរំលោភបំពាន តុលាការត្រូវគិតរយៈពេលទាំងស្រុង ចាប់ពីថ្ងៃឃាត់ខ្លួន ឬផ្តើមស៊ើបអង្កេតរហូតដល់ចេញសាលក្រម។[13] កត្តាដូចរៀបរាប់ខាងលើនឹងត្រូវពិចារណាទាំងស្រុងផងដែរ។ ការបង្កភាពយឺតយ៉ាវ ដោយជនសង្ស័យ អាចស្ថិតនៅក្នុងកម្រិតណាមួយ។ ការដាក់ញត្តិអនុញ្ញាតដោយច្បាប់របស់ជនសង្ស័យមិនត្រូវបានចាត់ថាជាឧបសគ្គនាំឲ្យយឺតយ៉ាវនៃនីតិវិធីទេ លុះត្រាការដាក់ញត្តិនោះជាការបំពានមិនមានហេតុផលសមស្រប ឬមានចេតនាពន្យារពេល។[14] បញ្ហានេះក៏ធ្លាប់ត្រូវលើកឡើងមុខ អ.វ.ត.ក ផងដែរ។[15]

នៅពេលរកឃើញថាមានការបំពានសិទ្ធិ មិនមែនតែសិទ្ធិ TRT ទេ តុលាការអន្តរជាតិ និងតុលាការជាតិបានផ្តល់នូវការជួសជុល (reparation) តិចឬច្រើនតាមក្របខ័ណ្ឌច្បាប់ និងការកំណត់ប្រភេទនៃការជួសជុល ដែលយល់ថាសមស្រប។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ប្រើពាក្យ "ការបំពេញចិត្តសមស្រប" (just satisfaction)[16] ដែលបើកចំហនូវច្រកទូលាយដល់តុលាការជាតិ ក្នុងការផ្តល់សំណងជូនជនរងគ្រោះ។[17] អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក បានសម្រេចផ្តល់សំណងដោយការដករយៈពេលនៃការជាប់ឃុំឃាំងខុសច្បាប់ ដោយតុលាការយោធាកម្ពុជា។

---

[12] Richard Clayton, Fair Trial Rights, 2006, point 11.138.

[13] Dovydas Vitkauskas and Grigory Dikov, Legal practitioners, *supra* note 5, p. 108.

[14] *Id.*, p. 110.

[15] ECCC Trial Chamber, Judgement of Case 002/2, 16 November 2018, E465, para.693.

[16] Q&A on the European Court of Human Rights award of "just satisfaction", https://www.echr.coe.int/Documents/Press_Q_A_Just_Satisfaction_ENG.pdf (accessed on 10 Oct 2021)

[17] Council of Europe, the length of civil and criminal proceedings in the case-law of the European Court of Human Rights, human rights files, No. 16, 1996.

*ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព អង្គជំនុំជម្រះយល់ឃើញថាជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ដែលអង្គជំនុំជម្រះនឹងត្រូវបានយកមកសម្រេចនៅដំណាក់កាលសម្រេចអំពីទោសរយៈពេល ដែលគាត់ជាប់ឃុំឃាំងដោយខុសច្បាប់នៅតុលាការយោធា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៩៩ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៧។*[18]

ចំពោះការបំពានសិទ្ធិ គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ បានថែងអំពីដំណោះស្រាយជាច្រើនប្រភេទ មានដូចជាការបន្ថយទោសការផ្តល់ឱកាសប្តឹងឡើងវិញដោយអះអាងថា÷ *រដ្ឋជាភាគីមានកាតព្វកិច្ចផ្តល់ដល់លោក Gridin នូវដំណោះស្រាយមានប្រសិទ្ធភាព មានជាសំណង និង ការដោះលែងជាបន្ទាន់...*។[19]

តុលាការខ្លះគ្រាន់តែចេញសាលក្រមប្រកាសថាបំពានសិទ្ធិ ដោយគ្មានផ្តល់សំណង (declaratory judgement)[20] ឬប្រកាសថា ច្បាប់ជាតិផ្ទុយនឹងច្បាប់សិទ្ធិមនុស្ស (declaration of conformity) ហើយដែលការអនុវត្តនាំឲ្យមានការបំពានសិទ្ធិ ដើម្បីស្នើឲ្យរដ្ឋសភាកែច្បាប់។[21]

តុលាការជប៉ុន ប្រកាសមោឃភាពនៃសេចក្តីសម្រេចរដ្ឋបាលដែលផ្ទុយនឹងវិធានសិទ្ធិមនុស្ស។[22] តុលាការរដ្ឋខ្លះបានប្រកាសឲ្យរដ្ឋទទួលខុសត្រូវ ក្នុងករណីបំពានសិទ្ធិចម្បងដោយអាជ្ញាធរ*...ប៉ូលិសបំពានច្បាប់ក្នុងអំឡុងពេលប្រតិបត្តិការការងាររបស់ខ្លួន...រដ្ឋបានខកខានបំពេញកាតព្វកិច្ចខ្លួនក្នុងការបង្រៀន និងបណ្តុះបណ្តាលប៉ូលិសស្តីពីវិធីសាស្ត្រ ការងារប៉ូលិសសមស្របនិងទទួលយកបាន ...ដូចនេះ វាជាការ*

[18] Trial Chamber of ECCC, Decision on Request for Release ( Public ), E39/5, 15 June 2009, para.36.

[19] *Smartt v. Guyana* ( 867/1999 ), ICCPR, A/59/40 vol. II ( 6 July 2004 ) 41 at para. 8; *Teesdale v. Trinidad and Tobago* ( 677/1996 ) ICCPR, A/57/40 vol. II ( 1 April 2002 ) 36 ( CCPR/C/74/D/677/1996 ) at para. 11; *Kennedy v. Trinidad and Tobago* ( 845/1998 ), ICCPR, A/57/40 vol. II ( 26 March 2002 ) 161 ( CCPR/C/74/D/845/1998 ) at para. 9; *Boodlal Sooklal v. Trinidad and Tobago* ( 928/2000 ), ICCPR, A/57/40 vol. II ( 25 October 2001 ) 264 ( CCPR/C/73/D/928/2000 ) at para.6.

[20] មាស បូរ៉ា និងលោក នូ គីមឈើវ, តួនាទីរបស់តុលាការក្នុងការការពារសិទ្ធិចម្បង (សិទ្ធិរួចផុតពីអំពើទារុណកម្ម), ឆ្នាំ ២០១៩, ទំ. ៩។

[21] ដូចខាងលើ។

[22] Dinah Shelton ed., International Law and Domestic Legal Systems, incorporation, Transformation, and Persuasion, 2011, p. 371.

*សមស្របដែលរដ្ឋត្រូវទទួលខុសត្រូវចំពោះអំពើបំពានរបស់ប៉ូលិស...*។[23] តុលាការជាតិខ្លះផ្តល់សំណងជាក់ស្តែងចំពោះការបំពានសិទ្ធិ ដូចជាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ រួមមានករណីការឃុំខ្លួនខុសច្បាប់ ឬការធ្វើទារុណកម្ម ដោយគិតគូរជាទឹកប្រាក់ជាក់ស្តែង÷ *ផ្តល់សំណងចំនួន ១០០,០០០ PGK សម្រាប់ការបំពានសិទ្ធិធម្មនុញ្ញ និងសំណងជាឧទាហរណ៍ចំនួន ២៥, ០០០ PGK*។[24]

## ៣. បទប្បញ្ញត្តិក្នុងច្បាប់កម្ពុជា

កម្ពុជាបានដាក់បញ្ចូលនូវសន្ធិសញ្ញាសិទ្ធិមនុស្ស មួយចំនួនក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[25] ដោយសារប្រព័ន្ធច្បាប់កម្ពុជាទទួលឥទ្ធិពលពីប្រព័ន្ធស៊ីវិលឡូរបស់បារាំង ហើយក្នុងដំណើរការផ្តល់សច្ចាប័នមានការចូលរួមយល់ព្រមជាមុនពីសភា សន្ធិសញ្ញាដែលត្រូវបានផ្តល់សច្ចាប័នរួចហើយមានសុពលភាពក្នុងស្រុក (domestic force)។[26] គេអាចអះអាងថា សន្ធិសញ្ញាសិទ្ធិមនុស្សអាចអនុវត្តផ្ទាល់ក្នុងប្រព័ន្ធច្បាប់ជាតិកម្ពុជាហើយ។[27] នេះត្រូវបានគាំទ្រដោយខ្លឹមសារនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ...។[28] អង្គជំនុំជម្រះតុលាការកំពូលរបស់ *អ.វ.ត.ក* ដែលមានចៅក្រមខ្មែរចំនួន ៤រូបបានអះអាងថាមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មអាចអនុវត្តផ្ទាល់បាន ដោយសារខ្លឹមសារនៃមាត្រានេះមានភាពច្បាស់លាស់...។[29] ដោយសារមាត្រា១៤ (៣.គ) ដកស្រង់ខាងលើ និងមាត្រាចែងអំពីសិទ្ធិទទួលបានដំណោះស្រាយ មានភាព

---

[23] National Court of Justice of Papua New Guinea, *Lamon v. Bumai*, [2010] PGNC 21, 12 March 2010, printed in 4 Pacific Human Rights Law Digest, 2013, p.1

[24] *Lamon v. Bumail*, Namdi v. Attorney General; *Namba v. Naru,* National Court of Justice, Papua New Guinea [2011] PGNC 124, 23, September 2011, p.2។ មួយដុល្លារសហរដ្ឋអាមេរិកស្មើ ៣.៥០១២៥ PGK។ សូមមើល មាស បូរ៉ា *តួនាទីរបស់តុលាការក្នុងការការពារសិទ្ធិចម្បង* លេខយោងទី ២០ ខាងលើ។ សូមមើលជាទូទៅផងដែរ Ken Oliphant (ed.), the liability of public authorities in comparative perspective, 2016.

[25] ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ នៃកម្ពុជា។

[26] Yuji Iwasawa, Domestic Application of International Law, 2015, p. 57.

[27] Mahdev Mohan, Cambodia in p. 506 *in* Simon Chesterman, Hisashi Owada and Ben Saul, the Oxford Handbook of International Law in Asia and the Pacific, 2019; CCPR Centre, replies of Civil society to the issues identified in the list of issues on Cambodian 2nd Report on ICCPR, 2015, p. 8.

[28] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៩២/០០៣/២០០៧/កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧។

[29] អង្គជំនុំជម្រះតុលាការកំពូល, សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក, F26/12, ៣១ ធ្នូ, ២០ ១៥, កថាខណ្ឌទី ៣៤។

ច្បាស់លាស់ដូចនេះ យើងអាចនិយាយបានថាមាត្រាទាំងនេះអាចស្វ័យអនុវត្តបាន (self-execution) ឬ អាចអនុវត្តដោយផ្ទាល់។

ពាក់ព័ន្ធនឹងសិទ្ធិ TRT ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងបញ្ចូលនូវខ្លឹមសារនៃមាត្រា១៤ (៣.គ) ទេ។ បទប្បញ្ញត្តិពាក់ព័ន្ធភាគច្រើននៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានចែងកំណត់ពេលដែលសវនាការត្រូវចាប់ផ្តើម ឬ អំឡុងពេលកំណត់ ដែលសវនាការត្រូវបញ្ចប់ទេ។

មាត្រាមួយចំនួន ដែលពាក់ព័ន្ធដូចជា ចែងតម្រូវឲ្យសវនាការត្រូវតែធ្វើឡើងក្នុងថ្ងៃបង្ហាញខ្លួនភ្លាមតែម្តង[30]។ សាលក្រមលើអង្គសេចក្តីត្រូវប្រកាសមិនលើសពីពីរសប្តាហ៍ គិតចាប់ពីថ្ងៃចូលបង្ហាញខ្លួន។[31] សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងពេលសមស្រប ហើយយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ថ្ងៃ ក្រោយថ្ងៃទទួលបានសំណុំរឿង។[32] តុលាការកំពូលត្រូវសម្រេចក្នុងក្នុងករណីពាក់ព័ន្ធនឹងបណ្តឹងស្តីពីការឃុំខ្លួនត្រូវសម្រេចរយៈពេល ៦ខែ គិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែជម្នះមិនបាន។[33] ចំពោះអនីតិជនវិញ គឺមានរយៈពេល ៣ខែ ក្រោយទទួលសំណុំរឿង លើកលែងជម្នះមិនបាន។[34] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចែងថា÷ *តុលាការ ត្រូវលើកមកសវនាការជាអាទិភាព ពិសេសក្មេងនៅក្នុងឃុំ បើលើកពេលអាចដោះលែងក្រៅឃុំ*។[35] ការបញ្ជូនពីសាលាដំបូង ទៅសាលាឧទ្ធរណ៍ ពីសាលាឧទ្ធរណ៍ ទៅតុលាការកំពូល ១០ ថ្ងៃ គិតពីចាប់ថ្ងៃប្តឹង លើកលែង តែមិនអាចជម្នះបាន។[36]

ការមិនកំណត់ពេលជាក់លាក់ធ្វើឲ្យនីតិវិធី ឬសវនាការមួយចំនួន មានភាពយឺតយ៉ាវ។ ឧបសម្ព័ន្ធភ្ជាប់នឹងអត្ថបទនេះ បានបង្ហាញនូវរយៈពេលរួម ចាប់ពីដំណាក់កាលនៅសាលាដំបូង រហូតដល់ សវនាការ

[30] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

[31] មាត្រា ៤៨ និង ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[32] មាត្រា ៣៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

[33] មាត្រា ៤៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

[34] មាត្រា ៥៧ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ ២០១៦។

[35] មាត្រា ៥៧ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ ២០១៦។

[36] មាត្រា ៥៦ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ ២០១៦។

ដោយតុលាការកំពូល។ រយៈពេលពន្យារអាចឆាប់ ឬក៏យូរ ដែលនាំឲ្យមានបំពានសិទ្ធិ អាស្រ័យទៅតាមសំណុំរឿងនីមួយៗ។ ប្រសិនបើសន្មត់ថា វាជាការបំពានសិទ្ធិ តើតុលាការកម្ពុជា មានសិទ្ធិក្នុងការផ្តល់សំណងដែរឬទេ? ប្រសិនបើមាន តើផ្អែកលើមូលដ្ឋានអ្វី? ហើយសំណងនោះ មានប្រភេទអ្វីខ្លះ?

ក្របខ័ណ្ឌច្បាប់កម្ពុជា ប្រសិនបើពិចារណាជារួម ផ្តល់ជាមូលដ្ឋានផ្លូវច្បាប់សម្រាប់តុលាការ ដោះស្រាយបញ្ហាបំពានសិទ្ធិមនុស្ស។ មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ បានចែងទទួលស្គាល់សិទ្ធិមនុស្ស។ មាត្រានៃរដ្ឋធម្មនុញ្ញដដែល បានចែងផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋប្តឹងតវ៉ាប្រឆាំងអង្គការរដ្ឋ ដើម្បីទារសំណង ហើយវាជាសមត្ថកិច្ចរបស់តុលាការក្នុងការសម្រេច។[37] ច្បាប់រដ្ឋធម្មនុញ្ញ បានចែងថា អំណាចតុលាការធានានូវសិទ្ធិសេរីភាពប្រជាពលរដ្ឋ។[38] ជាការអនុវត្ត តុលាការកំពូលបានអះអាងគាំទ្រថា÷ តុលាការត្រូវគិតពីសិទ្ធិរបស់ជនជាប់ឃុំឃាំង។[39] ជំហរនេះ មិនមានអ្វីប្លែកទេ។ តុលាការប្រទេសឥណ្ឌា អះអាងថា តុលាការត្រូវធានាថា មិនឲ្យមានការបំពានសិទ្ធិប្រជាពលរដ្ឋ។ នេះ បង្ហាញពីតួនាទីតុលាការ ដែលជាអង្គនៃអំណាចមួយក្នុងការអនុវត្តិសិទ្ធិមនុស្ស និងធ្វើឲ្យសិទ្ធិក្នុងក្រដាស ក្លាយជាការអនុវត្តជាក់ស្តែង។

ផ្អែកខាងលើបានបង្ហាញនូវប្រភេទការជួសជុលដូចជាការផ្តល់សំណង។ ច្បាប់កម្ពុជា ក៏ចែងនូវសំណងផងដែរសម្រាប់ការបំពានច្បាប់ ដូចជាច្បាប់ព្រហ្មទណ្ឌ។ ក៏ប៉ុន្តែមិនបាននិយាយអំពីសំណងជាក់លាក់សម្រាប់ការបំពានសិទ្ធិទេ ដូចនេះ ប្រភេទសំណងអ្វី វាជាឆន្ទានុសិទ្ធិរបស់ចៅក្រម។

ពាក់ព័ន្ធនឹងសំណង ក្រៅពីការលុបចោលដីការបស់អាជ្ញាធររដ្ឋបាល ដែលដីកានោះអាចផ្ទុយនឹងសន្ធិសញ្ញា និងនាំឲ្យប៉ះប្រយោជន៍ ឬសិទ្ធិប្រជាពលរដ្ឋ[40] ច្បាប់ដែលមានភាពផ្ទុយគ្នានឹងសន្ធិសញ្ញា ក៏នឹងនាំឲ្យមិនអាចអនុវត្តបាន។[41] សន្ធិសញ្ញា ដែលផ្ទុយនឹងអធិបតេយ្យបូរភាពដែនដី ក៏នឹងត្រូវមោឃភាពដែរ។[42]

---

[37] មាត្រា ៣៩ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣។

[38] មាត្រា ១២៨ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣។

[39] សាលដីកាតុលាការកំពូលលេខ ៣០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំ.១២។

[40] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១ មាត្រា ៤៩។

[41] ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ ២០០៣ កម្ពុជា, មាត្រា ៦៧។

សម្រាប់ពេលបច្ចុប្បន្ន វាមិនអាចទៅរួចទេ សម្រាប់តុលាការកម្ពុជា ក្នុងការចេញសំណងជាប្រាក់ចំពោះការបំពានសិទ្ធិ ដោយមន្ត្រី ឬតុលាការខ្លួនឯង ដោយសារ រដ្ឋមិនមានថវិកាគ្រប់គ្រាន់ដើម្បីចំណាយក្នុងរឿងនេះទេ។ អ្វីដែលសមស្រប គឺការកាត់បន្ថយទោស ជាការជួសជុលដល់ជនរងគ្រោះនៃការបំពានសិទ្ធិ។

**ទី១.** ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងអំពី មូលដ្ឋាននៃការសម្រាលទោស[43] ដែលបើកចំហជូនចៅក្រមសម្រេចតាមឆន្ទានុសិទ្ធិ ផ្អែកលើគោលការណ៍សមាមាត្រ និងឯកត្តកម្មនៃទោស[44]។ **ទី២.** ដូចបានអះអាងខាងលើ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ដែលមានចៅក្រមជាតិបីរូប បានបង្កើតជាយុត្តិសាស្ត្ររួចហើយ គឺការកាត់បន្ថយទោសជូន **ឌុច** ចំនួនប្រាំឆ្នាំ សម្រាប់ការឃុំខ្លួនខុសច្បាប់ដោយតុលាការយោធា (បំពានសិទ្ធិសុវត្ថិភាពបុគ្គល)។ ទីនេះ អ្នកនិពន្ធសូមអះអាងជាមុនចំពោះ អំណះអំណាងជាយថាហេតុដោយអ្នកស្រាវជ្រាវថា ខ្លឹមសារសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លែងមានសុពលភាពហើយដោយសារអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចដាក់ទោស*ឌុច* ជាប់ពន្ធនាគារមួយជីវិត។[45] ជាការពិតតុលាការកំពូល ទទួលស្គាល់ថា ការឃុំខ្លួន***ឌុច*** ខុសច្បាប់ និងសមទទួលបានការកាត់បន្ថយទោស ក៏ប៉ុន្តែដោយសារការឃុំខ្លួននោះ ដោយតុលាការយោធា មិនពាក់ព័ន្ធនឹង អ.វ.ត.ក ហើយបទល្មើសដែល ***ឌុច*** បានប្រព្រឹត្តគឺមានលក្ខណៈធ្ងន់ធ្ងរពេក។ ដូចនេះជម្រើសដ៏សមស្រប គឺដាក់ពន្ធនាគារមួយជីវិត។

ជាចុងក្រោយ មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា អំណាចតុលាការធានានូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ នេះជាមូលដ្ឋានរឹងមាំ ក្នុងការណ៍ដែលតុលាការជាតិលូកដៃ តាមរយៈការកាត់បន្ថយទោស។ ការសម្រេចដូចនេះ ជាប្រវត្តិសាស្ត្រក្នុងសេចក្តីសម្រេច ឬសាលក្រម ឬសាលដីកាណាមួយ នាពេលខាង

[42] មាត្រា ៥៥ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[43] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩, មាត្រា ៩៣។

[44] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩, មាត្រា ៩៦។

[45] ECCC, Supreme Court Chamber, Appeal Judgement, 3 February 2012, F28, III. disposition, p.320.

មុខ ពិតជាជួយជំរុញឲ្យអាជ្ញធរមានសមត្ថកិច្ចពាក់ព័ន្ធ ខិតខំជំរុញការងារឲ្យបានឆាប់មិនយឺតយ៉ាវ។ បើមិនដូចនេះទេ ជនជាប់ចោទនឹងទទួលបាននូវការសម្រាលទោស។

ចៅក្រមជាអាជ្ញាធរនៃអង្គអំណាចតុលាការ ហើយបើមានការបំពានសិទ្ធិ តាមរយៈការខកខានមិនបានចូលរួមធានា ឬការពារសិទ្ធិ វាគ្រប់គ្រាន់ហើយក្នុងការអះអាងថា រដ្ឋទាំងមូលបំពានសិទ្ធិ ទោះបីមានតែរដ្ឋាភិបាលទេ ដែលផ្តល់សច្ចាប័នដល់សន្ធិសញ្ញា។[46] និយាយបញ្ច្រាសមកវិញ ការសម្រេចសេចក្តី ដោយចៅក្រមក្នុងការបន្ថយទោស សម្រាប់ជាសំណងសម្រាប់ការបំពានសិទ្ធិ ជាការជួយគោរព កាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់សំណង អនុលោមតាមសន្ធិសញ្ញាសិទ្ធិមនុស្សដែលរដ្ឋជាភាគី។

## ៤. សង្ខេប

សិទ្ធិទទួលបានសវនាការក្នុងពេលសមស្របដើម្បីធានានូវយុត្តិធម៌ តាមរយៈការបង្ការនូវការបាត់បង់ភស្តុតាង ឬការចងចាំរបស់សាក្សី។ សិទ្ធិនេះ ជាសិទ្ធិចម្បងមួយនៃសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្តីប្រកបដោយយុត្តិធម៌។ ការបំពានសិទ្ធិនេះ ប៉ះដល់ប្រយោជន៍នៃជនរងគ្រោះ នឹងនាំឲ្យមានសំណងជុសជុល ដូចជាការការបន្ថយទោសក្នុងពន្ធនាគារ ដែលជាសមត្ថកិច្ចរបស់តុលាការ។

## ៥. បញ្ជីឯកសារយោង

ក្នុងការសរសេរអត្ថបទខ្លីនេះ អ្នកនិពន្ធបានពិគ្រោះនូវឯកសារមួយចំនួនខាងក្រោម។ ក៏ប៉ុន្តែ ដើម្បីជួយផ្សព្វផ្សាយឯកសារដ៏ល្អផ្សេងទៀតខាងក្រោមទាំងនេះ អ្នកនិពន្ធសម្រេចដាក់ក្នុងបញ្ជីទាំងអស់។ អ្នកនិពន្ធមានឯកសារទាំងអស់នេះទាំងជា soft copy ផង។ ក្នុងករណីអ្នកស្រាវជ្រាវចង់បានសូមទាក់ទងមករយៈតាម email: b_meas@yahoo.com

1. OSCE, legal digest of fair trial rights, 2012.

[46] General Comment no. 31 of the UN Human Rights Committee on the Nature of the General Legal Obligation imposed on States Parties to the Covenant, CCPR/C/21/Rev.1/Add. 13, 26 May 2004, para.4.

2. Johann Bair, the International Covenant on Civil and Political Rights and Its (First) Optional Protocol, 2005.

3. Gudmundur Alfredsson, the Universal Declaration of Human Rights, 1999.

4. Jeremy McBride, Human rights and criminal procedure, 2009.

5. Louise Doswald and et al., Judicial Process and human rights, 2004.

6. EU Network of Independent Experts on Fundamental Rights, Commentary of the Charter of Fundamental Rights of the European Union, 2006.

7. European Union Agency for Fundamental Rights, Handbook on European Law relating to access to justice, 2016.

8. DovydasVitkauskas and Grigory Dikov, Protecting right to a fair trial under the European Convention on Human Rights: A Handbook for legal practitioners, 2nd ed., 2017.

9. Directorate General of Human Rights and Legal Affairs Council of Europe, the right to trial within a reasonable time and short-term reform of the European Court of Human Rights, 2009.

10. Council of Europe, the length of civil and criminal proceedings in the case-law of the European Court of Human Rights, human rights files, No. 16, 1996.

11. Ben Emmerson and et al., Human Rights and Criminal Justice, 2nd ed., 2007.

12. Stefano Maffei, the European Right to Confrontation in Criminal Proceedings, 2006.

13. Olaoluwa Olusanya, Double Jeopardy without parameters, 2004.

14. Social Fieldwork Research (FRANET), Presumption of Innocence: procedural rights in criminal proceedings, Case Study of Germany, https://fra.europa. eu/sites/default/files/fra_uploads/germany-2021-country-research-presumption-innocence_en.pdf

15. Christina Peristeridou, Principle of Legality in European Criminal Law, 2015.

16. Colin Wells, Abuse of Process, 2006.

17. Stephen C. Thaman, Exclusionary Rules in Comparative Law, 2013.

18. Andrew L-T Choo, Abuse of Process and Judicial Stays of Criminal Proceedings, 2n ed., 2008.

19. J R Spencer, Evidence of Bad Character, 3rd Ed., 2016.

20. Sarah Summers, Fair Trials, 2007.

21. Bjorn Elberling, the Defendant in International Criminal Proceedings: between law and historiography, 2012.

22. Stefan Trechsel, Human Rights in Criminal Proceedings, 2006.

23. J.A. Andrews, Human Rights in Criminal procedure: A comparative study, 1982.

24. Richard Clayton, Fair Trial Rights, 2006.

25. Elmar Widder, A Fair Trial at the International Criminal Court? Human Rights Standards and Legitimacy, 2016.

26. Ed Cape and Zaza Namoradze, Effective Criminal Defence in Eastern Europe, 2012.

27. Toward a prosecutor for the European Union, 2012, Vol. 1.
28. Dato Param Cumaraswamy, Human Rights in Criminal Justice Systems, 2009.
29. Masha Fedorova, the Principle of Equality of Arms in International criminal proceedings, 2012.
30. Drazan Djukic, the right to appeal in international criminal law, 1981.
31. John B. Taylor, Right to Counsel and Privilege against Self-incrimination, 2004.
32. Salvatore Zappala, Human rights in international criminal proceedings, 2005.
33. Silvia Allegrezza, Effective Defence Rights in Criminal Proceedings, 2018.
34. Zaza Namoradze, Effective Criminal Defence in Latin America, 2015.
35. International Commission of Jurists, Commentary on Berlin Declaration, 2008.
36. Herman Melville, Judicial review and human rights act, 2000.
37. Martin Kuijer, the right to a fair trial and the Council of Europe's efforts to ensure effective remedies on a domestic level for excessively lengthy proceedings, 2013.
38. Interights, rights to a fair trial under the Euroepan Convention on Human rights, 2009.
39. Nuala Mole, the Right to a fair trial, Human rights handbooks, No. 3, 2006.
40. Grigoriy Dikov, Protecting the right to a fair trial under the European Convention on Human Rights, 2012.

## ឧបសម្ព័ន្ធទី១÷ ភ្ជាប់នឹងអត្ថបទស្រាវជ្រាវស្តីពីសិទ្ធិទទួលបានសវនការក្នុងពេលសមស្រប

## (ពេលវេលារួមសម្រាប់សំណុំរឿងនីមួយៗ)

**<u>កំណត់សំគាល់÷</u>** រយៈពេលក្នុងតារាងនេះ គ្រាន់តែជាការបង្ហាញទេ។ មិនអាចទាន់ត្រូវបានបង្ហាញថារយៈពេលនេះ យឺតយូរដោយគ្មានហេតុផលនោះទេ។ ការអាចសន្និដ្ឋានបានដូម្តេច ផ្អែកទៅតាមអង្គហេតុនៃសំណុំរឿងនីមួយៗ។

| ល.រ | ជនជាប់ចោទ | បទចោទ និងសំណុំរឿង | រយៈពេលនៃនីតិវិធី | | | រយៈពេលសរុប |
|---|---|---|---|---|---|---|
| | | | តុលាការក្រុង/ខេត្ត | សាលាឧទ្ធរណ៍ | តុលាការកំពូល | |
| ១ | រ.ប. អាយុ២០ឆ្នាំ | ជួញដូរ និងប្រើប្រាស់សារធាតុញៀន។ សំណុំរឿង ៤៤ ថ្ងៃ ៥ មីនា ២០២០ (កំពូល)។ មករា ២០១៨ (កើតហេតុ) | គុក៦ឆ្នាំ (សម្រេចក្នុងខែ កញ្ញា ២០១៨) ៨ ខែក្រោយថ្ងៃកើតហេតុ | សម្រេចក្នុងខែ មករា ឆ្នាំ ២០២០ (ទោស ៥ឆ្នាំ)។ ២ឆ្នាំ ក្រោយកើតហេតុ។ សវនាការលើកទី២មិនទាន់មាន | សម្រេច ៩ ខែកញ្ញា ២០២០។ បង្វិលទៅសាលាឧទ្ធរណ៍ (ទោស២ឆ្នាំ ខែ ៩ ខែក្រោយកើតហេតុ) | ២ឆ្នាំ ៩ ខែ |
| ២ | ស.ស. (អាយុ | រំលោភមានស្ថានទម្ងន់ពាក់ព័ន្ធជនរងគ្រោះ។ សំណុំ | កាត់ទោស ៧ឆ្នាំ សវនាការ ទី៣ ខែ | ២៥ ខែមីនា ឆ្នាំ ២០២០ (តម្កល់) ១ឆ្នាំ បីខែ | ២១ តុលា ២០២០ (តម្កល់) ១ឆ្នាំ ១០ ខែ | ១ឆ្នាំ ១០ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៦១ឆ្នាំ) | រឿងតុលាការកំពូលលេខ ១១៦ ថ្ងៃទី ១២ មិថុនា ២០២០។ កើតហេតុ ២៥ ធ្នូ ២០១៨ | តុលា ឆ្នាំ ២០១៩ (១០ ខែ ក្រោយ កើតហេតុ) | ក្រោយកើតហេតុ | ក្រោយកើតហេតុ | |
| ៣ | ម. រ (អាយុ ៤១ឆ្នាំ) | លេខ ៧១ ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០២០ របស់កំពូល។ ផិត និង អាសប្រឆាំងនឹងអនីតិជន អាយុក្រោម ១៥ឆ្នាំ កើតហេតុ ក្នុងឆ្នាំ ២០១០ | ខែសីហា ឆ្នាំ ២០ ១១ (លើកលែង ចោទ) យ៉ាងតិច ៨ខែ | ខែ ៤ ឆ្នាំ ២០១២ (តម្ក ល់លើកលែងចោទ) ប្រ ហែល ១ឆ្នាំ ៤ ខែក្រោយ កើតហេតុ | ២១ ខែមេសា ឆ្នាំ ២០២១ (តម្កល់ដីកា លើកលែងចោទ)រយៈ ពេលជាង ១១ ឆ្នាំ | រយៈពេល ជាង ១១ឆ្នាំ |
| ៤ | B. D. N. (អាយុ៥៣ ឆ្នាំ) | បទទិញពេស្យាចារកុមារ។លេខ ២១៧ (កំពូល) ៥ តុលា ឆ្នាំ ២០២០។ កើតហេតុថ្ងៃទី ២៣ ឧសភា ២០១៥ | ១៤ មិថុនា ២០១៦ សម្រេចដាក់គុក ១០ឆ្នាំ។ ប្រហែ ល១ឆ្នាំ ក្រោយ កើតហេតុ | សីហា ២០២០ (តម្កល់) ៥ឆ្នាំ ៣ខែ ក្រោយកើត ហេតុ។មិនទាន់សវនាការ លើកទី២ទេ។ | ១៧ កុម្ភៈ ២០២១ ( បង្វិលទៅសាលាឧទ្ធ រណ៍)៥ឆ្នាំ ៩ខែ ក្រោ យកើតហេតុ | ៥ឆ្នាំ ៩ខែ |
| ៥ | ន. ផ (អាយុ | មនុស្សឃាដគិតទុកជាមុន កើត | មេសា២០១១ សវ | សវនាការ តុលា ២០១២ | សវនាការ ខែកញ្ញា | ៤ឆ្នាំ ៩ ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| | ២៥ឆ្នាំ) | ហេតុ ខែ ធ្នូ ២០០៨ (លេខ ៥៩ ក្រុងភ្នំពេញ មករា ២០០៩) | នាការទោស ១៥ឆ្នាំ (២ឆ្នាំ ៣ ខែ ក្រោយកើតហេតុ) | (តម្កល់)។ ៣ឆ្នាំ ៩ខែ ក្រោយកើតហេតុ | ២០១៣ (បញ្ជូនត្រឡប់ទៅវិញ)។ ៤ឆ្នាំ ៩ ខែ | |
| ៦ | អ.ស (អាយុ ២៨ឆ្នាំ) | ជួញដូរ និងប្រើប្រាស់សារធាតុញៀន។ សំណុំរឿង ២៥៩ ថ្ងៃ ១៣ វិច្ឆិកា ២០២០ (កំពូល)។ ២១ កុម្ភៈ ២០១៩ (កើតហេតុ) | ខែកក្កដា២០១៩ ។ដាក់ពន្ធនាគារ ១៣ ឆ្នាំ (៥ខែ ក្រោយកើតហេតុ) | ខែ កញ្ញា ឆ្នាំ ២០២០។ ១១ ឆ្នាំ។ ១ឆ្នាំ ៧ខែ | ៣១ មីនាឆ្នាំ ២០២១។ ២ឆ្នាំ ១ ខែ ក្រោយកើតហេតុ | ២ឆ្នាំ ១ ខែ |
| ៧ | ខាំបៃ (អាយុ ៥២ឆ្នាំ) | ជួញដូរដោយប្រើប្រាស់នូវសារធាតុគ្រឿង។ លេខ ៧៥ ចុះថ្ងៃទី ១៣ មីនា ២០១៩ (កំពូល)។ ធ្នូ ២០១២ កើតហេតុ | ទោស ២៥ឆ្នាំ។ មករា ឆ្នាំ ២០១៤។ ២ឆ្នាំក្រោយ កើតហេតុ | មិថុនា ២០១៨។ សម្រេចរួចផុតចោទ។ ៥ឆ្នាំ ៦ខែ ក្រោយកើតហេតុ | **បដិសេធ**។ មករា ២០២១។ | ៩ឆ្នាំ |
| ៨ | ម.រ. (អាយុ ២៨ឆ្នាំ) | មីនា ២០០៩ (កើតហេតុ)។ ១១ ខែមីនា ២០០៩ (កំពត)។ ឃាតកម្មគិតទុកជាមុន | កុម្ភៈ ២០១០ (សវនាការ) រួចផុតចោទប្រកាន់។១ | កុម្ភៈ ២០១២ (សវនាការ)។ដាក់គុក ១០ឆ្នាំ។ ៣ឆ្នាំ (ក្រោយកើតហេតុ) | វិច្ឆិកា ២០១៣ (សវនាការ)។ បង្វិលទៅវិញ។ ៤ឆ្នាំ ៩ខែ | ៤ឆ្នាំ ៩ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ឆ្នាំក្រោយកើតហេតុ | | | |
| ៩ | អ.ស (អាយុ ៣៣ឆ្នាំ) | ប៉ុនប៉ងរំលោភ។ កញ្ញា ២០០៧ (កើតហេតុ)។ ១៥០ ចុះថ្ងៃទី ១៧ កញ្ញា ២០០៧ (ក្រចេះ) | កញ្ញា២០០៩ (សវនាការ)។ រួចខ្លួនពីចោទ។ ២ឆ្នាំក្រោយកើតហេតុ | មីនា ២០១១ (សវនាការ) ។១០ឆ្នាំ។ ៣ឆ្នាំ ៦ខែ ក្រោយកើតហេតុ | មីនា ២០១៤ (សវនាការ)។បង្វិល។ ៦ឆ្នាំ ៦ខែ | ៦ឆ្នាំ ៦ខែ |
| ១០ | គ.ស.ក (អាយុ ២០ឆ្នាំ) | ប៉ុនប៉ងរំលោភ។ កុម្ភៈ ២០០៦ (កើតហេតុ)។ ៥៥៨ ចុះថ្ងៃ ២០ កក្កដា ២០០៦ (ឧទ្ទរណ៍) | មិថុនា២០០៦ (សវនាការ)។ រួចផុតពីបទចោទ។ ៤ ខែ ក្រោយកើតហេតុ | កក្កដា ២០០៨ (សវនាការ)។ កែប្រែទៅជារំលោភ និងដាក់គុក ១៥ឆ្នាំ។ ២ឆ្នាំ ក្រោយកើតហេតុ | កុម្ភៈ ២០១២ (សវនាការ) បង្វិលទៅវិញ។ ៥ឆ្នាំ ៧ខែ | ៥ឆ្នាំ ៧ខែ |
| ១១ | ស. វ. (អាយុ ២០ឆ្នាំ) | រួមភេទជាមួយក្មេងក្រោម១៥ឆ្នាំ។ វិច្ឆិកា ២០០៩ (កើតហេតុ)។ ២៧៥១ ខែ ១១ ឆ្នាំ ២០០៩ (ភ្នំពេញ) | មីនា ២០១១ (សវនាការ)ទោស ៥ឆ្នាំ។ ១ឆ្នាំ ៤ខែ ក្រោយកើតហេតុ | មេសា ២០១២(សវនាការ)។ តម្កល់។ ២ឆ្នាំ ៥ខែ ក្រោយកើតហេតុ | កញ្ញា ២០១៣។ បង្វិល។ ៣ឆ្នាំ ១០ ខែ | ៣ឆ្នាំ ១០ ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | ច.ធ.យ. (អាយុ២២ឆ្នាំ | អំពើអនាចារ ថ្ងៃទី ៧ សីហា ២០០៦។ ១៧៦១ ខែ សីហា ឆ្នាំ ២០០៦ (ភ្នំពេញ) | មីនា ២០០៧ (សវនាការ) ទោស១៧ ឆ្នាំ។ ៧ ខែក្រោយកើតហេតុ | មីនា ២០១០ (សវនាការ) តម្កល់សាលក្រម។ ៣ឆ្នាំ ៧ខែ | កញ្ញា ២០១៣ (សវនាការ) បង្វិល។ ៧ឆ្នាំ | ៧ ឆ្នាំ |
| ១៣ | អ.ផ. (អាយុ៤០ឆ្នាំ) | អូសទាញពេស្យាចារកុមារ។ ៤៥១ ចុះ កុម្ភៈ ឆ្នាំ ២០១០ (ភ្នំពេញ) កើតហេតុ កុម្ភៈ ២០១០ | មករា ២០១១ (សវនាការ) ៣ឆ្នាំ ក្នុងគុក។ ១១ ខែ | មករា ២០១២ (សវនា-ការ) តម្កល់។ ២ឆ្នាំ | មីនា ២០១៤ (សវនាការ) បង្វិល។ ៤ឆ្នាំ | ៤ឆ្នាំ |
| ១៤ | ជ.ស.ខ. (អាយុ ២៥ឆ្នាំ) | ១៦១១ ខែ កក្កដា ២០០៥ (ភ្នំពេញ) កើតហេតុ កក្កដា ២០០៤ (ប្លន់ និងប្រើអាវុធខុសច្បាប់) | សីហា២០០៦ (សវនាការ) ៦ឆ្នាំគុក។ ១ឆ្នាំ | មេសា ២០០៨ (សវនាការ) តម្កល់។ ២ឆ្នាំ ៩ខែ | កុម្ភៈ ២០១២ (សវនាការ)តម្កល់។៥ឆ្នាំ ៧ខែ | ៥ឆ្នាំ ៧ខែ |
| ១៥ | ស.រ.ត. (អាយុ១៩ឆ្នាំ) | ១១១៩ ខែ មិថុនា ២០០៨ (ភ្នំពេញ)។ ប្លន់។ មិថុនា ២០០៨ (កើតហេតុ) | កក្កដា២០១០ (សវនាការ) ជាប់ទោស៦ឆ្នាំ។ ២ឆ្នាំក្រោ | កុម្ភៈ ២០១២ (សវនាការ)។ ប្តូរពីប្លន់ទៅ ប៉ុនប៉ងលួចដោយហិង្សា (ពី ៦ឆ្នាំ | ធ្នូ ២០១៣ (សវនាការ)។ បញ្ជូនទៅវិញ មើលទោស។ ៤ឆ្នាំ ៦ខែ | ៤ឆ្នាំ ៦ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | យកើតហេតុ | ទៅ ៣ឆ្នាំ)។ ៣ឆ្នាំ ៨ខែ | | |
| ១៦ | ភ.ផ.ដ.ណ. (អាយុ ២៥ឆ្នាំ) | ១២ ខែ កក្កដា ២០០៧ (ភ្នំពេញ)។ប្លន់។ មិថុនា ២០០៧ (កើតហេតុ) | មីនា ២០០៨ (សវនាការ)។ ទោស ៥ ឆ្នាំ។ ៩ ខែ | កក្កដា ២០១១ (សវនាការ)។ ៤ឆ្នាំ ក្រោយកើតហេតុ។ ប្តូរពីទោស ៥ឆ្នាំ មក ៤ឆ្នាំ | ធ្នូ ២០១៣ (សវនាការ) បង្វិលឱ្យមើលបទចោទ។៥ឆ្នាំ ៥ ខែ | ៥ឆ្នាំ ៥ ខែ |
| ១៧ | ស.ល.អ. (អាយុ ២១ឆ្នាំ) | ៦៨៨ ខែ មីនា ២០០៩ (ភ្នំពេញ)។ ឆក់ខ្សែក (ប្លន់)។ មីនា ២០០៩ (កើតហេតុ) | កញ្ញា ២០០៩ (សវនាការ)។ ទោស ៧ឆ្នាំ។ ៦ខែ | វិច្ឆិកា ២០១០ (សវនាការ)។តម្កល់។ ១ឆ្នាំ៨ខែ ក្រោយកើតហេតុ | ធ្នូ ២០១៣ (សវនាការ)។ បង្វិលឱ្យមើលផ្នែកខ្លះ។ ៤ឆ្នាំ ៩ខែ | ៤ឆ្នាំ ៩ខែ |
| ១៨ | អ.រ.ហ. (អាយុ ២៣ឆ្នាំ) | ១៧៨៩ ខែ កញ្ញា ឆ្នាំ ២០០៨ (ភ្នំពេញ)។ លួចមានគ្នាច្រើន (ប្លន់) កញ្ញា ២០០៨ | ទោស ៥ឆ្នាំ។ ឧសភា ២០១០ (សវនាការ)។១ឆ្នាំ ៨ខែ | ឧសភា ២០១២ (សវនាការ)។ ទោស ១ឆ្នាំ ពីបទទទួលផលចោរ។៣ឆ្នាំ ៨ខែ | តុលា ២០១៣ (សវនាការ)។បង្វិលឱ្យគិតរឿងទោស (ជនត្រូវចោទផ្សេង)។ ៤ឆ្នាំ។ | ៤ឆ្នាំ |
| ១៩ | ល.ស.ខ. (អាយុ៥៦ឆ្នាំ) | ២៥៦០ ខែ សីហា ២០១២ (ភ្នំពេញ) ហិង្សាដោយចេតនាមាន | ធ្នូ ២០១២ (សវនាការ) ទោស ៣ឆ្នាំ។ | សីហា ២០១៣ (សវនាការ)។ កែជាបទផ្តើម | វិច្ឆិកា ២០១៣។ បង្វិលឱ្យ មើលទោស។ | ១ឆ្នាំ បីខែ |

| | | | | | | |
|---|---|---|---|---|---|---|
| | | ស្ថានទម្ងន់ (សីហា ២០១២) | ៤ខែ | គំនិតប្រព្រឹត្តហិង្សា។ ២ឆ្នាំ គុក ១ឆ្នាំ ព្យួរធម្មតា។ ១ឆ្នាំក្រោយកើតហេតុ | ១ឆ្នាំ ៣ខែ | |
| ២០ | វ.ណ.រ. (អាយុ៤៦ឆ្នាំ) | ៨២១ ខែ វិច្ឆិកា ២០០៦ (បាត់ដំបង)។ បង្ករបួសស្នាមមានអាវុធ និង ជេរប្រមាថ (កញ្ញា ២០០៤) | មិថុនា ២០០៧ (សវនាការ) ទោស ៦ខែ តែព្យួរ។ ៧ខែ | ឧសភា ២០០៩ (សវនាការ)។ តម្កល់។ ២ឆ្នាំ ៦ ខែ | មករា ២០១៤ (សវនាការ)។ បង្វិល ។ ៧ឆ្នាំ ២ខែ | ៧ឆ្នាំ ២ខែ |
| ២១ | ស.យ. (អាយុ ៣៨ឆ្នាំ) | ៥៧៥ ខែ មីនា ២០០៧ (ភ្នំពេញ)។ផ្តល់សក្ខីកម្មក្លែង (តុលា ២០០៤) | កក្កដា២០០៩ (សវនាការ)។ ទោស ១ឆ្នាំ។ ២ឆ្នាំ ៤ ខែ | កុម្ភៈ ២០១១ (សវនាការ)។ តម្កល់សាលក្រម។ ៤ ឆ្នាំ | ធ្នូ ២០១៣ (សវនាការ)។រួចផុតពីចោទ ដោយសារ ជនល្មើសមិនមែនជាប្រធាននៃបទសក្ខីកម្មក្លែងទេ។៥ឆ្នាំ ១០ ខែ | ៥ឆ្នាំ ១០ខែ |

| | | | | | | |
|---|---|---|---|---|---|---|
| ២២ | ជ.ស.ណ. (អាយុ ២២ឆ្នាំ) | ២៣៨ ខែ ឧសភា ២០០៧ (បាត់ដំបង)។ បង្កអគ្គិភ័យដោយចេតនា (តុលា ២០០៦)។ | មីនា ២០០៨ (សវនាការ)។ ទោស ១ឆ្នាំ។ ១០ខែ | ធ្នូ ២០០៩ (សវនាការ)។ តម្កល់ និងឱ្យសងសំណង។ ១ឆ្នាំ ៧ខែ | កុម្ភៈ ២០១៤ (សវនាការ)។ បង្វិលទៅជម្រះវិញ។ ៦ឆ្នាំ ៩ខែ | ៦ឆ្នាំ ៩ខែ |
| ២៣ | អ.ស. (អាយុ ៤៣ឆ្នាំ) | ៣៧៨ ខែ មិថុនា ២០១០ (កំពង់ចាម)។ បរិហារ និងជេរ (កក្កដា ២០០៧)។ | សីហា២០១០ (សវនាការ)។ ពិន័យមួយលានរៀល។ ២ខែ | កក្កដា ២០១១។ តម្កល់។ ១ឆ្នាំ | កញ្ញា ២០១៣ (សវនាការ)។បង្វិល។ ៣ឆ្នាំ ៣ខែ | ៣ឆ្នាំ ៣ខែ |
| ២៤ | អ.ឌ.ឡ.ទ. (អាយុ៤៤ឆ្នាំ) | ៣៨៨ ខែ កុម្ភៈ ២០១២ (ភ្នំពេញ)។ មិនបំពេញកាតព្វកិច្ច និងរំលោភលើទំនុកចិត្ត (មិថុនា ២០០៩) | កក្កដា ២០១២ (សវនាការ)។ ទោស ៣ឆ្នាំ។ ៧ខែ | មករា២០១៣ (សវនាការ)។ តម្កល់។ ១ឆ្នាំ | កុម្ភៈ ២០១៤ (សវនាការ)បង្វិលឱ្យពិនិត្យមើលសំណងរដ្ឋប្បវេណី។ ២ឆ្នាំ | ២ឆ្នាំ |